ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MOSALVY

ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៣៣៨ សកបយ

ភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការគ្រប់គ្រងពលករបរទេស

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យ លេខ ៥៧អនក្រ/បក ចុះថ្ងៃ ទី ០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញ លិខិតលេខ ១១៦៦ សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការគ្រប់គ្រងពលករបរទេស ជាភាសាអង់គ្លេសហៅថា Foreign Workers Administering Committee "FWAC" ស្ថិតនៅក្នុងអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាល

វិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ដើម្បីគ្រប់គ្រងពលករបរទេសទាំងអស់ដែលចូលមកប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ ស្តីពីការងារ ។

**ប្រការ ២:** គណៈកម្មការគ្រប់គ្រងពលករបរទេស មានភារកិច្ចដូចតទៅ:

១- រៀបចំបែបបទនានា ស្តីពីការស្នើសុំយកពលករបរទេសមកប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ បែបបទនេះត្រូវដាក់ជូនទៅនាយកដ្ឋានជំនាញរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីពិនិត្យ និងសំរេច ស្របទៅតាមករណីជាក់ស្តែងនីមួយៗ ។

២- រៀបចំបែបបទជាផ្លូវការស្តីពីការដាក់អោយពលករបរទេសធ្វើការនៅក្នុងសហគ្រាសគ្រឹះស្ថាននានាក្រោយពេលដែលសហគ្រាស គ្រឹះស្ថានទាំងនោះទទួលបានការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

៣- សហការជាមួយក្រសួងមហាផ្ទៃ តំណាងការងារទូតប្រទេសដើមរបស់ពលករបរទេស និងសមាគមនិយោជក និងនិយោជក ដើម្បីដោះស្រាយរាល់ការងារដែលពាក់ព័ន្ធជាមួយពលករបរទេស ។

៤- សហការជាមួយនាយកដ្ឋានជំនាញ ដើម្បីពង្រឹងការងារអធិការកិច្ចពលករបរទេស និងទំនាក់ទំនង វិជ្ជាជីវៈរវាងពលករបរទេស និងនិយោជក ។

**ប្រការ ៣:** បង្កើតលេខាធិការដ្ឋានមួយនៅក្នុងនាយកដ្ឋានមុខរបរ និងហត្ថពលកម្មជាជំនួយការរបស់គណៈកម្មការគ្រប់គ្រងពលករបរទេស ដែលមានមន្ត្រីជំនាញបំរើការមកពីនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ ។

សមាសភាពមន្ត្រីនៃលេខាធិការដ្ឋានមាន:

| | | |
|---|---|---|
| ១-លោក ហ៊ូ វុឌ្ឍី | អគ្គនាយករងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២-លោក គ្រួច សុផារី | អគ្គនាយករងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣-លោក សេង សក្ក | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | អនុប្រធាន |
| ៤-លោក ឃួន ឡានិច | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ៥-លោក ចេត សំអឿន | អនុប្រធានការិយាល័យស្ថិតិមុខរបរ និងហត្ថពលកម្ម | សមាជិក |

៦-លោក ឃុន ពិសិដ្ឋារ៉ា មន្ត្រីការិយាល័យត្រួតពិនិត្យជនបរទេស សមាជិក

៧-លោក ជូរ រតនៈ មន្ត្រីនាយកដ្ឋានពេទ្យការងារ សមាជិក

៨-លោក ជួន ឃុន មន្ត្រីនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ សមាជិក

មន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលភារកិច្ចនៅក្នុងលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងពលករបរទេសត្រូវបានរក្សាក្របខ័ណ្ឌ បៀវត្ស ការតំឡើងឋានៈ និងការលើកសរសើរនៅអង្គភាពដើម ។

**ប្រការ ៤:** ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នាយកដ្ឋានបច្ចេក ទេសវិជ្ជាជីវៈ និងទីផ្សារការងារ នាយកដ្ឋានពេទ្យការងារ និងមន្ត្រីដែលទទួលភារកិច្ចនៅក្នុងប្រការ ៣ ត្រូវអនុវត្តប្រកាសនេះប្រកបដោយប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៥:** ត្រូវចាត់ទុកជានិរាករណ៍នូវប្រកាសលេខ ២៨៤ សកបយ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ របស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្តីពីការបង្កើតអង្គភាពពលករបរទេស ។

**ប្រការ ៦:** រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

អ៊ិត សំហេង

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-សមាគមនិយោជក នៃព្រះរាជាណាចក្រកម្ពុជា "ដើម្បីជ្រាប"
-ដូចប្រការ ៣ និងប្រការ ៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ